**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

# ផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈ ឆ្នាំ២០១៤

## ១.សេចក្តីផ្តើម

កម្ពុជា ជាព្រះរាជាណាចក្រដែលមានសម្បត្តិវប្បធម៌ដ៏សំបូរបែប ដូចជាប្រាង្គប្រាសាទបុរាណប្រកបទៅដោយក្បាច់រចនាចម្លាក់រស់រវើក ល្អប្រណិត ដែលជាផ្នែកមួយនៃបេតិកភណ្ឌវប្បធម៌ដ៏ថ្លៃថ្លារបស់ជាតិ ព្រមទាំងមានរមណីយដ្ឋានប្រវត្តិសាស្ត្រជាច្រើនកន្លែងទៀតផង។ ក្រៅពីប្រាសាទបុរាណដែលជាបេតិកភណ្ឌវប្បធម៌រូបី យើងនៅមានបេតិកភណ្ឌវប្បធម៌អរូបីជាច្រើនទម្រង់ ច្រើនប្រភេទទៀតដូចជា ចម្រៀង របាំ ល្ខោន ទំនៀមទំលាប់ប្រពៃណីជាដើម ដែលបុព្វបុរសដូនតាយើងបានកសាងទុកជាកេរមរតកវប្បធម៌សំរាប់ខ្មែរជំនាន់ក្រោយទាំងអស់គ្នាមានកាតព្វកិច្ចថែរក្សា ការពារ ឲ្យនៅស្ថិតស្ថេរ គង់វង្ស ព្រោះសម្បត្តិវប្បធម៌ទាំងអស់នោះមានប្រយោជន៍មិនអាចកាត់ថ្លៃបាន ជាស្នូលនៃអត្តសញ្ញាណខ្មែរ ជាពិសេសជាប្រភពសក្តានុពលមិនចេះរីងស្ងួតសំរាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រជូនប្រជាជន។

ដើម្បីសម្រេចបាននូវកាតព្វកិច្ចខាងលើនេះ និងបន្តចូលរួមជំរុញការថែរក្សា ការពារ លើកតម្កើងកេរតំណែលវប្បធម៌ជាតិ អភិវឌ្ឍសកម្មភាពវប្បធម៌គ្រប់ជំនាញ ជំរុញផលិតកម្ម សិប្បកម្មវប្បធម៌ លើកទឹកចិត្តការបង្កើតស្នាដៃថ្មី ផ្សព្វផ្សាយអំពីផលិតផលវប្បធម៌ខ្មែរដ៏សំបូរបែប និងស្វែងរកទីផ្សារសម្រាប់ផលិតផលវប្បធម៌របស់ប្រជាជន រួមចំណែកកាត់បន្ថយភាពក្រីក្រជូនប្រជាជន ព្រមទាំងអប់រំអំពីវប្បធម៌ និងសីលធម៌ដ៏ល្អប្រពៃរបស់ជាតិ ទប់ស្កាត់ការហូរចូលឥតឈប់ឈរនៃវប្បធម៌អវិជ្ជមានពីបរទេស កាត់បន្ថយសកម្មភាពមិនល្អក្នុងស្រទាប់យុវជនដែលធ្វើឲ្យប៉ះពាល់ដល់វប្បធម៌ប្រពៃណី ទំនៀមទំលាប់ដ៏ល្អផូរផង់របស់ជាតិ ជាពិសេសដើម្បីបំរើឲ្យ**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ក្នុងនីតិកាលទី៥ នៃរដ្ឋសភា** ដែលជារបៀបវារៈគោលនយោបាយសង្គមសេដ្ឋកិច្ច របស់រាជរដ្ឋាភិបាល ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានខិតខំ និងសហការជាមួយស្ថាប័នរដ្ឋ និងឯកជនគ្រប់ជំនាញ ក្នុងគោលបំណងប្រែក្លាយ**វប្បធម៌ជាសេដ្ឋកិច្ចជាតិ** ស្របតាមគោលនយោបាយវប្បធម៌ **អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ** ដែលរដ្ឋជាអ្នកគ្រប់គ្រង ឯកជនជាដៃគូអនុវត្ត។

## ២.ចក្ខុវិស័យ

ផ្អែកតាមលទ្ធផលការងារ និងបញ្ហាប្រឈមដែលទទួលបាន និងជួបប្រទះក្នុងរយៈកាលកន្លងមកយើងពិនិត្យឃើញថា វប្បធម៌ជាស៊ីម៉ង់ត៍រស់ដែលជាកត្តាចាំបាច់បំផុតនៃសាមគ្គីភាព សន្តិភាព សុខដុមភាព ព្រមទាំងជាមូលដ្ឋានគ្រឹះនៃលំហូរទេសចរណ៍ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តភាព នោះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានប្រកាន់យក **សក្តានុពលវប្បធម៌ជាមូលដ្ឋានគ្រឹះ នៃសេដ្ឋកិច្ចជាតិ** ជាចក្ខុវិស័យ និងជាត្រីវិស័យសម្រាប់រៀបចំកម្មវិធីការងាររបស់ខ្លួន ដើម្បីឈានទៅធានា និងសំរេចឲ្យបាននូវការអនុវត្តគោលនយោបាយវប្បធម៌គឺៈ **អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ** ។

## ៣.គោលបំណង

**វប្បធម៌ជាសេដ្ឋកិច្ចជាតិ** ជាគោលបំណងនៃការអភិរក្ស និងអភិវឌ្ឍវប្បធម៌ដើម្បីថែរក្សាការពារបេតិកភណ្ឌវប្បធម៌ទាំងរូបី និងអរូបីឲ្យស្ថិតស្ថេរគង់វង្សយូរអង្វែងតទៅ ចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព រក្សាបាននូវតម្លៃ និងវិសាលភាពវប្បធម៌ ក្នុងបេសកកម្ម**ដឹកនាំ និងគ្រប់គ្រងវិស័យវប្បធម៌នៅទូទាំងព្រះរាជាណាចក្រកម្ពុជា**។

## ៤.គោលដៅ

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានខិតខំបំពេញបេសកម្មរបស់ខ្លួនតាមរយៈការប្រើប្រាស់សក្តានុពលវប្បធម៌ទាំងរូបី និងអរូបីជាថាមពល និងជាកត្តាជំរុញក្នុងការបង្កបង្កើតសេវា និងផលិតផលវប្បធម៌ថ្មីៗឲ្យកាន់តែសំបូរបែប ពង្រីកទីផ្សារវប្បធម៌កាន់តែទូលំទូលាយ ក្នុងគោលដៅ **កម្ពុជាៈ ព្រះរាជាណាចក្រនៃវប្បធម៌** ។

## ៥.យុទ្ធសាស្ត្រ

ដើម្បីធានា និងសម្រេចបានប្រកបដោយជោគជ័យនូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានកំណត់យកផែនការយុទ្ធសាស្ត្រចំនួន៣ជាគោលក្នុងការអនុវត្តសកម្មភាពការងារវប្បធម៌របស់ខ្លួនក្នុងឆ្នាំ២០១៤ ដូចខាងក្រោមៈ

**ផែនការយុទ្ធសាស្ត្រទី១: ពង្រឹង ពង្រីកសក្តានុពលវប្បធម៌ឲ្យក្លាយជាកម្លាំងចលករក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ**
**ផែនការយុទ្ធសាស្ត្រទី២: ពង្រឹង ពង្រីកការអប់រំ ផ្សព្វផ្សាយ ការច្នៃប្រឌិត និងការបង្កើតទីផ្សារវប្បធម៌**
**ផែនការយុទ្ធសាស្ត្រទី៣: ពង្រឹង ពង្រីកសមត្ថភាពស្ថាប័ន ភាពជាដៃគូអភិវឌ្ឍ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងសេវា**

ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនស្របតាម **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣** និងដើម្បីធ្វើឲ្យសម្រេចបាននូវផែនការយុទ្ធសាស្ត្រទាំង៣ខាងលើនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានដាក់ចេញនូវផែនការសកម្មភាពការងារឆ្នាំ២០១៤ ដូចតទៅៈ

## ៦.ផែនការសកម្មភាពការងារវប្បធម៌ និងវិចិត្រសិល្បៈ ឆ្នាំ២០១៤
## របស់អង្គភាពថ្នាក់កណ្តាល នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

| **ផែនការយុទ្ធសាស្ត្រទី១ [3] ពង្រឹងពង្រីកសក្តានុពលវប្បធម៌ឲ្យក្លាយជាកម្លាំងចលករក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ** | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ផែនការអាទិភាពទី១. បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ ដើម្បីស្វែងរកមូលនិធិទ្រទ្រង់ដល់ការជួសជុលវត្ថុបុរាណ និងសំណង់បុរាណ** | | | | | | | | | | | | | | |
| ផែនការសកម្មភាព | រយៈពេលអនុវត្ត | | | | | | | | | | | | អង្គភាពទទួលខុសត្រូវ | ប្រភពថវិកា |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | | |
| ១.១.១ ស្វែងរកមូលនិធិជាមួយដៃគូអភិវឌ្ឍ ដើម្បីទ្រទ្រង់ដល់ការជួសជុលសំណង់បុរាណនានា | | | | | | | | | | | | | នា.គាំពារ | រដ្ឋ |
| ១.១.២ ស្វែងរកមូលនិធិទ្រទ្រង់ដល់ការសិក្សា ស្រាវជ្រាវស្ថានីយបុរាណនានា | | | | | | | | | | | | | នា.បុរាណវិទ្យា | រដ្ឋ |
| ១.១.៣ ស្វែងរកមូលនិធិសំរាប់ធ្វើជួសជុល និងវិភាគវត្ថុបុរាណព្រមទាំងការអប់រំផ្សព្វផ្សាយ | | | | | | | | | | | | | នា.បុរាណវត្ថុ | រដ្ឋ |
| ១.១.៤ សហការសិក្សា ស្រាវជ្រាវជាមួយវិទ្យាស្ថានជាតិណារ៉ា **ប្រទេសជប៉ុន** សកលវិទ្យាល័យអូតាហ្គោ **ប្រទេសញ៉ូសេឡែន** វិទ្យាស្ថានស្រាវជ្រាវ អភិវឌ្ឍ និងសារមន្ទីរជាតិប្រវត្តិធម្មជាតិវិទ្យានៃទីក្រុងប៉ារីស **ប្រទេសបារាំង** | x | x | x | | | | | | | | | x | នា.បុរាណវិទ្យា | ដៃគូ |
| ១.១.៥ ពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិលើការងារឯកសារសារមន្ទីរ | x | x | x | x | x | x | x | x | x | x | x | x | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| ១.១.៦ បន្តសាងសង់ព្រះពុទ្ធរូបអង្គធំ នៅឃុំបឹងដែង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម | x | x | x | x | x | x | x | x | x | x | x | x | ក្រសួង | រដ្ឋ និងសប្បុរសជន |
| **ផែនការអាទិភាពទី២. លើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ** | | | | | | | | | | | | | | |
| ១.២.១ បន្តស្រង់ស្ថិតិស្ថានីយបុរាណ និងរមណីយដ្ឋានប្រវត្តិសាស្ត្រ ដើម្បីស្នើសុំបញ្ចូលជាសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិ ខេត្តកំពង់ធំ កណ្តាល កំពង់ស្ពឺ ព្រៃវែង បន្ទាយមានជ័យ កំពង់ចាម ក្រចេះ និងស្ទឹងត្រែង | | | | | | | | x | x | | | | នា.បុរាណវិទ្យា | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.២.២ បន្តចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈ និងសមុច្ច័យនៅសារមន្ទីរជាតិ ចូលក្នុងប្រព័ន្ធកុំព្យូទ័រ និងឆ្លោះទៅសារមន្ទីររាជធានី ខេត្ត | | | | | | x | | | | | | | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| ១.២.៣ បន្តបោះបង្គោល និងស្លាកសញ្ញាការពារស្ថានីយបុរាណ និងរមណីយដ្ឋានប្រវត្តិសាស្ត្រនៅខេត្តកណ្តាល កំពង់ស្ពឺ តាកែវ ស្វាយរៀង និងកំពង់ចាម | | | | | | | | | | x | x | | នា.បុរាណវិទ្យា | រដ្ឋ |
| ១.២.៤ ទប់ស្កាត់ការជីកកកាយ ការឈូសឆាយបំផ្លាញ ឬការសង់សំណង់ផ្សេងៗលើស្ថានីយបុរាណ និងរមណីយដ្ឋានប្រវត្តិសាស្ត្រ | | | | | | | | | | | | | នា.បុរាណវិទ្យា | រដ្ឋ |
| ១.២.៥ បន្តជួសជុលស្ពានហាលខាងត្បូង (បញ្ចប់) និងជួសជុលខ្លោងទ្វារខាងត្បូង នៃប្រាសាទបន្ទាយឆ្មា ខេត្តបន្ទាយមានជ័យ | | | | | | x | x | x | x | x | x | | នា.គាំពារ | រដ្ឋ |
| ១.២.៦ ថែទាំ និងជួសជុលស្ពានទ័ព១៥១មខេត្តបន្ទាយមានជ័យ | | | x | x | x | x | x | x | x | x | x | x | នា.គាំពារ | រដ្ឋ |
| ១.២.៧ ថែទាំ និងជួសជុលប្រាសាទបាណន់ ខេត្តបាត់ដំបង | | | | | | | x | x | x | x | | | នា.គាំពារ | រដ្ឋ និងដៃគូ |
| ១.២.៨ ជួសជុលប្រាសាទស្នឹងបន្ត (ជំហានទី២) ខេត្តបាត់ដំបង | | | | | | | | | x | x | x | x | នា.គាំពារ | រដ្ឋ |
| ១.២.៩ ថែទាំ ជួសជុល និងទល់ទ្រប្រាសាទចាន និងប្រាសាទល្បើកស្នាច់ ខេត្តឧត្តរមានជ័យ | | | | | | | | | x | x | x | | នា.គាំពារ | រដ្ឋ |
| ១.២.១០ ជួសជុល និងថែទាំប្រាសាទS8 (ក្រុមប្រាសាទយាយព័ន្ធ នៃក្រុមប្រាសាទសម្បូណ៌ព្រៃគុក) ប្រាសាទភ្នំជីសូរ្យ ប្រាសាទ បាណន់ ប្រាសាទស្នឹង និងប្រាសាទទ័ព | | | | | | | | | | | | | នា.គាំពារ | រដ្ឋ |
| ១.២.១១ ជួសជុលអាគារ និងរូបចម្លាក់ នៅអភិរក្សដ្ឋានអង្គរ និងធ្វើជើងទម្រតម្កល់រូប | | | | | | | | | | | | | នា.គាំពារ | រដ្ឋ |
| **ផែនការអាទិភាពទី៣. សិក្សា ស្រាវជ្រាវពីបេតិកភណ្ឌវប្បធម៌ដែលកំពុងប្រឈមនឹងគ្រោះថ្នាក់ ដើម្បីអភិរក្ស** | | | | | | | | | | | | | | |
| ១.៣.១ បន្តសិក្សាស្រាវជ្រាវ កំណត់ទីតាំង និងផ្ទៀងផ្ទាត់ស្ថានីយបុរាណ រមណីយដ្ឋានប្រវត្តិសាស្ត្រ តាមបណ្តាខេត្ត និងកំណត់តំបន់សក្តានុពលវិស័យទេសចរណ៍វប្បធម៌ | | | x | x | x | x | x | x | x | x | x | | នា.បុរាណវិទ្យា | រដ្ឋ |
| ១.៣.២ បន្តប្រមូលព័ត៌មានទីតាំងបុរាណវត្ថុ ដែលស្ថិតនៅក្រៅ | x | x | x | x | x | x | x | x | x | x | x | x | នា.បុរាណវត្ថុ | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឃ្លាំង និងធ្វើការចុះបញ្ជីសារពើភណ្ឌ និងប្រមូលបុរាណវត្ថុលើទីតាំងចំនួន៥កន្លែង ដែលងាយរងការបំផ្លិចបំផ្លាញខ្លាំង | | | | | | | | | | | | | | |
| ១.៣.៣ បន្តធ្វើកំណាយស្រាវជ្រាវនៅស្ថានីយល្អាងស្ពាន ក្នុងខេត្តបាត់ដំបង | | | | | | | | | | | | | នា.បុរាណវិទ្យា | រដ្ឋ និងដៃគូ |
| **ផែនការអាទិភាពទី៤. ជំរុញឲ្យកម្ពុជា ក្លាយជាមជ្ឈមណ្ឌលផ្សព្វផ្សាយសិល្បៈទស្សនីយភាព** | | | | | | | | | | | | | | |
| ១.៤.១ ពង្រឹងសមត្ថភាពជំនាញ និងជួយកែលម្អស្នាដៃសិល្បៈមហាជន និងអង្គការ សមាគមសិល្បៈ លើទម្រង់របាំ និងតន្ត្រីរបាំក្បាច់បុរាណ **អ៊ីណាវបុស្បា** | | | | x | x | | | | | | | | នា.សិល្បៈទស្សនីយភាព | រដ្ឋ |
| ១.៤.២ ពង្រឹងសមត្ថភាពជំនាញ និងជួយកែលម្អស្នាដៃសិល្បៈមហាជន និងអង្គការ សមាគមសិល្បៈ លើទម្រង់ល្ខោន និងល្ខោនចម្រុះ **អប្សរាកេរដូនតា** | | | | | | | | x | x | | | | នា.សិល្បៈទស្សនីយភាព | រដ្ឋ |
| ១.៤.៣ ពង្រឹងសមត្ថភាពជំនាញ និងជួយកែលម្អស្នាដៃសិល្បៈមហាជន និងអង្គការ សមាគមសិល្បៈ លើទម្រង់របាំ និងតន្ត្រីរបាំប្រពៃណី **មេឃស្រទ្បះហើយ** | | | | | | | | | | | x | x | នា.សិល្បៈទស្សនីយភាព | រដ្ឋ |
| ១.៤.៤ សិក្សា ស្រាវជ្រាវ ចងក្រង និងតម្លើងស្នាដៃសិល្បៈទស្សនីយភាព | | | x | x | | | | | | | | | នា.សិល្បៈទស្សនីយភាព | រដ្ឋ |
| ១.៤.៥ ធ្វើបបកថា និងបង្ហាត់សិល្បៈនៅតាមគ្រឹះស្ថានសិក្សា មន្ទីររាជធានី-ខេត្ត អង្គការ និងសង្គមស៊ីវិល | x | x | x | x | x | x | x | x | x | x | x | x | នា.សិល្បៈទស្សនីយភាព | រដ្ឋ |
| ១.៤.៦ តម្លើងស្នាដៃតន្ត្រី សិល្បៈទស្សនីយភាពសម្តែងបំរើព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ | | | x | | | x | | | x | | | x | នា.សិល្បៈទស្សនីយភាព | រដ្ឋ |
| **ផែនការអាទិភាពទី៥ លើកកម្ពស់ការទាក់ទាញក្រុមហ៊ុនថតភាពយន្តបរទេសឲ្យមកថតភាពយន្តនៅកម្ពុជា** | | | | | | | | | | | | | | |
| ១.៥.១ សិក្ខាសាលា ស្តីពី **តួនាទីភាយន្ត និង ការប្រឈម** | | | | | | | | | | | x | | នា.ភាពយន្ត | រដ្ឋ |
| ១.៥.២ ផលិតវីដេអូឯកសារ និងបច្ចុប្បន្នភាព | x | x | x | x | x | x | x | x | x | x | x | x | នា.ភាពយន្ត | រដ្ឋ |
| ១.៥.៣ ធ្វើការផ្សព្វផ្សាយ ដើម្បីទាក់ទាញការថតភាពយន្តបរទេស | | | | | | | x | | | x | x | | នា.ភាពយន្ត | រដ្ឋ |
| ១.៥.៤ ប្រមូល ថែរក្សាសម្ភារៈបម្រើឲ្យការរៀបចំថតភាពយន្ត | x | x | x | x | x | x | x | x | x | x | x | x | នា.ភាពយន្ត | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.៥.៥ ផ្តល់សេវាអនុញ្ញាតការថតភាពយន្តបរទេស | x | x | x | x | x | x | x | x | x | x | x | x | នា.ភាពយន្ត | រដ្ឋ |
| ១.៥.៦ ផ្តល់ទិដ្ឋាការ និងអនុញ្ញាតឲ្យថតភាពយន្តក្នុងស្រុក | x | x | x | x | x | x | x | x | x | x | x | x | នា.ភាពយន្ត | រដ្ឋ |
| ១.៥.៧ ផ្តល់អាជ្ញាប័ណ្ណផលិតកម្មភាពយន្ត | x | x | x | x | x | x | x | x | x | x | x | x | នា.ភាពយន្ត | រដ្ឋ |
| ១.៥.៨ រៀបចំមហោស្រពភាពយន្តជាតិ (រឿង និងឯកសារ) | | | | | | | | | | | x | | នា.ភាពយន្ត | រដ្ឋ |
| ១.៥.៩ រៀបចំមហោស្រពភាពយន្តអាស៊ាន និងអន្តរជាតិ | | | | | | | | | | | | x | នា.ភាពយន្ត | រដ្ឋ |
| **ផែនការអាទិភាពទី៦. ជម្រុញឲ្យកម្ពុជា ជាទីកន្លែងផ្សព្វផ្សាយផលិតផលសិល្បៈសូនរូប និងសិប្បកម្ម** | | | | | | | | | | | | | | |
| ១.៦.១ សិក្សាស្រាវជ្រាវអំពីខ្នាត និងក្បាច់ចម្លាក់ខ្មែរភាគ៣ | x | x | x | x | x | x | x | x | x | x | x | | នា.សិល្បៈសូនរូប | រដ្ឋ |
| ១.៦.២ បោះពុម្ពសៀវភៅខ្នាតក្បាច់ចម្លាក់ខ្មែរភាគ២ | | | | | | | x | x | x | x | x | x | នា.សិល្បៈសូនរូប | រដ្ឋ |
| ១.៦.៣ បណ្តុះបណ្តាលក្បួនខ្នាត ក្បាច់ចម្លាក់ខ្មែរដល់ សហគម និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ៤ខេត្ត | | | | x | x | x | x | x | x | x | x | x | នា.សិល្បៈសូនរូប | រដ្ឋ |
| ១.៦.៤ បន្តការចុះធ្វើបទបង្ហាញស្តីពី អត្តសញ្ញាណចម្លាក់ខ្មែរ និងផ្សព្វផ្សាយកម្មវិធីចុះបញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌អរូបីតាមទម្រង់ ICH.IN.01/ICH.IN.02 និងបំប៉នមន្ត្រីរាជការរៀបគ្រប់គ្រងតាមបណ្តាខេត្ត២៤ | x | x | x | x | x | x | x | x | x | x | x | x | នា.សិល្បៈសូនរូប | រដ្ឋ |
| **ផែនការយុទ្ធសាស្ត្រទី២ [3] ពង្រឹងពង្រីកការអប់រំ ផ្សព្វផ្សាយ ការថ្លៃប្រឌិត និងការបង្កើតទីផ្សារវប្បធម៌** | | | | | | | | | | | | | | |
| **ផែនការអាទិភាពទី១. លើកកម្ពស់ការអប់រំ បណ្តុះបណ្តាល ដោយឈរលើគោលការណ៍ (ការអប់រំដើម្បីវប្បធម៌ វប្បធម៌ដើម្បីការអប់រំ)** | | | | | | | | | | | | | | |
| ២.១.១ លើកកម្ពស់គុណភាពបណ្តុះបណ្តាល នៅគ្រប់កម្រិតសិក្សា ស្របតាមការណែនាំរបស់ក្រសួងអប់រំយុវជន និងកីឡា | | | | | | | | x | x | | | | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | រដ្ឋ |
| ២.១.២ កែប្រែកម្មវិធីសិក្សាឲ្យស្របតាមស្តង់ដាជាតិ និងតំបន់ | x | x | x | x | x | x | x | x | x | x | x | x | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | រដ្ឋ |
| ២.១.៣ បន្តធ្វើការកែទម្រង់ និងធ្វើឲ្យប្រសើរឡើងនូវការងារគ្រប់គ្រងការសិក្សា | x | x | x | x | x | x | x | x | x | x | x | x | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | រដ្ឋ |
| ២.១.៤ បន្តការប្រើប្រាស់ ការបង្រៀនគ្រូឲ្យតន្ត្រី និងមុខវិជ្ជាផ្សេងៗទៀតតាម Online ឬសិក្សា តាមរយៈ Video Conference ដោយសហការ ជាមួយអតិរក្សដ្ឋានតូរ្យតន្ត្រីសឹង្ហបុរី នៃសាកលវិទ្យាល័យជាតិសឹង្ហបុរី | | | x | | | | | | | | | | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.១.៥ បន្តបញ្ជូននិស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេស | | | | | | | x | x | | | | | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | រដ្ឋ |
| ២.១.៦ បន្តរៀបចំកម្មវិធីសិក្សាឲ្យស្របតាមស្តង់ដាររបស់ក្រសួងអប់រំ | x | x | x | x | x | x | x | x | x | x | x | x | សាលាមធ្យមវិចិត្រសិល្បៈ | រដ្ឋ |
| ២.១.៧ ធ្វើការស្រាវជ្រាវ ចងក្រង និងបោះពុម្ពសៀវភៅអប់រំសិក្សា | x | x | x | x | x | x | x | x | x | x | x | x | សាលាមធ្យមវិចិត្រសិល្បៈ | រដ្ឋ |
| ២.១.៨ រៀបចំការប្រឡងសញ្ញាបត្រសិល្បៈ និងស្នាតកបត្រសិល្បៈក្នុងឆ្នាំសិក្សា ២០១៣-២០១៤ | | | | x | | x | x | x | | | | | សាលាមធ្យមវិចិត្រសិល្បៈ | រដ្ឋ |
| ២.១.៩ រៀបចំប្រឡងជ្រើសរើសសិស្សចូលរៀនឆ្នាំសិក្សា ២០១៤-២០១៥ | | | | | | | | x | | | | | សាលាមធ្យមវិចិត្រសិល្បៈ | រដ្ឋ |
| ២.១.១០ ជំរុញការបណ្តុះបណ្តាលសិស្ស និស្សិត ដែលបញ្ចប់ការសិក្សានៅថ្នាក់មធ្យម និងឧត្តម ដើម្បីបំពេញគរុកោសល្យនៅក្រសួងអប់រំ | | | | | | | | | | | | | សាលាមធ្យមវិចិត្រសិល្បៈ | រដ្ឋ |
| **ផែនការអាទិភាពទី២. លើកកម្ពស់ការផ្សព្វផ្សាយ ដើម្បីបង្កើននូវការយល់ដឹងពីតម្លៃពិត នៃវប្បធម៌ ប្រពៃណី ទំនៀមទំលាប់របស់ជាតិ និងភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌** | | | | | | | | | | | | | | |
| ២.២.១ បន្តការសិក្សា និងចងក្រងនូវល្បែងប្រជាប្រិយ៍ដែលមាននៅទូទាំងប្រទេស | x | x | x | x | x | x | x | x | x | x | x | x | នា.អភិវឌ្ឍវប្បធម៌ | រដ្ឋ |
| ២.២.២ រៀបចំសហការជាមួយសហគមវប្បធម៌គំរូមួយនៅខេត្តរតនគីរី ដើម្បីស្រាវជ្រាវពីប្រពៃណីជនជាតិដើមភាគតិច | x | x | x | x | x | x | | | | | | | នា.អភិវឌ្ឍវប្បធម៌ | រដ្ឋ |
| ២.២.៣ ស្រាវជ្រាវ និងបើកសិក្ខាសាលា ស្តីពីជនជាតិដើមភាគតិចខេត្តរតនគីរី | | | | x | x | x | | | | | | | នា.អភិវឌ្ឍវប្បធម៌ | រដ្ឋ |
| ២.២.៤ បើកសិក្ខាសាលា ស្តីអំពីអាពាហ៍ពិពាហ៍ខ្មែរ | | | | | | | x | x | x | | | | នា.អភិវឌ្ឍវប្បធម៌ | រដ្ឋ |
| ២.២.៥ បោះពុម្ពទស្សនាវដ្តី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | | | x | | | | x | | | | x | នា.សៀវភៅ ការអាន | រដ្ឋ |
| ២.២.៦ រៀបចំតាំងពិព័រណ៍សៀវភៅថ្នាក់ជាតិ | | | | | | | | | | | x | | នា.សៀវភៅ ការអាន | រដ្ឋ |
| ២.២.៧ រៀបចំប្រឡងជ្រើសរើសស្នាដៃតែងនិពន្ធ ប្រលោមលោក និងកំណាព្យរឿង | | | | | x | x | x | x | x | x | | | នា.សៀវភៅ ការអាន | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.២.៨ ទិញសៀវភៅតម្កល់ទុកក្នុងបណ្ណាល័យជាតិ | | | | | | | | x | x | x | | | នា.សៀវភៅ ការអាន | រដ្ឋ |
| ២.២.១០ ចងក្រង និងបោះពុម្ពឯកសារទាក់ទងកម្មសិទ្ធិបញ្ញា ដើម្បីផ្សព្វផ្សាយ | | x | x | x | x | | | | | | | | នា.សិទ្ធិអ្នកនិពន្ធ | រដ្ឋ |
| - សរសេរទិន្នន័យកម្មសិទ្ធិបញ្ញាបញ្ចូល ក្នុងWebsite | x | x | x | x | x | x | x | x | x | x | x | x | | |
| - បោះពុម្ពសន្ធិសញ្ញាក្រុងប៊ែន (Berne Convention) | | x | | | | | | | | | | | | |
| - បោះពុម្ពច្បាប់សិទ្ធិអ្នកនិពន្ធបន្ថែម | | | x | | | | | | | | | | | |
| ២.២.១១ បើកសិក្ខាសាលា ដើម្បីធ្វើការផ្សព្វផ្សាយ ស្តីពីសិទ្ធិអ្នកនិពន្ធ | | | | x | | | | | | | | | នា.សិទ្ធិអ្នកនិពន្ធ | រដ្ឋ |
| - សិក្ខាសាលា ស្តីពីអង្គភាពគ្រប់គ្រងសិទ្ធិរួម | | | | | | x | | | | | | | | |
| - ផ្សព្វផ្សាយបទដ្ឋានគតិយុត្តិសម្រាប់ អនុវត្តកម្មសិទ្ធិបញ្ញា | | | | | | | | x | x | | | | | |
| ២.២.១២ ចុះដកបទពិសោធន៍ និងសម្តែងបង្ហាញស្នាដៃសិល្បៈនៅមូលដ្ឋាន | | | | | | | | | | | | | សាលាមធ្យមវិចិត្រសិល្បៈ | រដ្ឋ |
| **ផែនការអាទិភាពទី៣. បង្កើនការគាំទ្រ និងលើកទឹកចិត្តដល់ការច្នៃប្រឌិតបង្កើតថ្មីលើគ្រប់ផ្នែកក្នុងវិស័យវប្បធម៌** | | | | | | | | | | | | | | |
| ២.៣.១ រៀបចំសកម្មភាពទិវាកម្មសិទ្ធិបញ្ញា | | | | x | | | | | | | | | នា.សិទ្ធិអ្នកនិពន្ធ | រដ្ឋ |
| **ផែនការអាទិភាពទី៤. លើកកម្ពស់ការយកចិត្តទុកដាក់បង្កើតទីផ្សារវប្បធម៌** | | | | | | | | | | | | | | |
| ២.៣.១ ផ្សព្វផ្សាយរាល់សកម្មភាពការងារក្នុងវិស័យវប្បធម៌តាមប្រព័ន្ធអ៊ីនធឺណែត | x | x | x | x | x | x | x | x | x | x | x | x | នា.រដ្ឋបាល | រដ្ឋ |
| **ផែនការអាទិភាពទី៥. រៀបចំមហោស្រពតាំងបង្ហាញស្នាដៃបង្កើតថ្មី និងផលិតផលឧស្សាហកម្មច្នៃប្រឌិត** | | | | | | | | | | | | | | |
| ២.៥.១ ចូលរួមក្នុងការរៀបចំពិព័រណ៍វប្បធម៌ខ្មែរ អន្តរជាតិ និងអាស៊ាន | x | x | x | x | x | x | | | | | | | នា.អភិវឌ្ឍវប្បធម៌ | រដ្ឋ |
| ២.៥.២ រៀបចំមហោស្រពសិល្បៈសូនរូប ស្តីពីចម្លាក់ឈើ | | | | | | | x | x | x | x | x | x | នា.សិល្បៈសូនរូប | រដ្ឋ |
| ២.៥.៣ រៀបចំពិព័ណ៌អចិន្ត្រៃយ៍ ស្តីពីសិល្បៈសូនរូបនៅសាលសន្និសីទចតុម្មុខ | x | x | x | x | x | x | x | x | x | x | x | x | នា.សិល្បៈសូនរូប | រដ្ឋ |
| **ផែនការអាទិភាពទី៦. លើកកម្ពស់ការរៀបចំព្រឹត្តិការណ៍វប្បធម៌ប្រចាំឆ្នាំដូចជា៖ ទិវាវប្បធម៌ជាតិ ពិធីបង្ហោះខ្លែង មហោស្រពសិល្បៈ មហោស្រពម្ហូបអាហារខ្មែរ ការបង្ហាញម៉ូដ និងការប្រឡងចម្រៀង** | | | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.៦.១ រៀបចំមហោស្រពសិល្បៈ អាយ៉ៃ ចាប៉ី និទានរឿង តាមភូមិភាគ | | | | | | | | | | x | | | នា.សិល្បៈទស្សនីយភាព | រដ្ឋ |
| ២.៦.២ រៀបចំមហោស្រពសិល្បៈតន្ត្រី ចម្រៀង របាំ ល្ខោន តាមភូមិភាគ | | | | | | | | | | x | | | នា.សិល្បៈទស្សនីយភាព | រដ្ឋ |
| ២.៦.៣ រៀបចំមហោស្រពខ្លែង សិល្បៈដណ្តាំស្លម្ហូបអាហារខ្មែរ និងទម្រង់សំលៀកបំពាក់ខ្មែរ | | | | | | | x | x | x | x | x | x | នា.អភិវឌ្ឍវប្បធម៌ | រដ្ឋ |
| ២.៦.៤ រៀបចំមហោស្រពចម្រៀងខ្មែរជាសាកលឆ្នាំ២០១៤ | | | | | | | | | | | | | ក្រសួង | រដ្ឋ និង សប្បុរសជន |
| **ផែនការយុទ្ធសាស្ត្រទី៣ ៖ ពង្រឹងពង្រីកសមត្ថភាពស្ថាប័ន ភាពជាដៃគូអភិវឌ្ឍ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងសេវា** | | | | | | | | | | | | | | |
| **ផែនការអាទិភាពទី១. បន្តពង្រឹងបែបបទ និងនិតិវិធីរដ្ឋបាល ឲ្យកាន់មានប្រសិទ្ធភាព និងគុណភាពក្នុងការផ្តល់សេវាលើវិស័យវប្បធម៌** | | | | | | | | | | | | | | |
| ៣.១.១ បន្តពង្រឹង និងជម្រុញការគ្រប់គ្រង និងកែសម្រួលបែបបទការនាំចេញ នាំចូលវត្ថុសិល្បៈឲ្យកាន់តែមានភាពសាមញ្ញ រហ័ស និងសុវត្ថិភាព | x | x | x | x | x | x | x | x | x | x | x | x | នា.បុរាណវត្ថុ | រដ្ឋ |
| ៣.១.២ ផ្តល់សេវាចុះបញ្ជីស្នាដៃ និងសុំសិទ្ធិធ្វើអាជីវកម្មលើ៖ | | | | | | | | | | | | | នា.សិទ្ធិអ្នកនិពន្ធ | រដ្ឋ |
| -ស្នាដៃគ្មានមរតកសាសន៍ | x | x | x | x | x | x | x | x | x | x | x | x | | |
| -ការបោះពុម្ពស្នាដៃ | x | x | x | x | x | x | x | x | x | x | x | x | | |
| -ការនាំចេញ នាំចូលនូវស្នាដៃអក្សរសាស្ត្រ | x | x | x | x | x | x | x | x | x | x | x | x | | |
| -ការនាំចេញ នាំចូល ផលិតឌីសអុបទិកនិងឧបករណ៍ថតចម្លង | x | x | x | x | x | x | x | x | x | x | x | x | | |
| ៣.១.៣ កែសម្រួលការគ្រប់គ្រង ការចរាចរលិខិតរដ្ឋបាល និងសម្របសម្រួលអោយទាន់ពេលវេលា | x | x | x | x | x | x | x | x | x | x | x | x | នា.រដ្ឋបាល | រដ្ឋ |
| ៣.១.៤ រៀបចំគោលការណ៍គ្រប់គ្រងលិខិតរដ្ឋបាលឲ្យមានលក្ខណៈជាច្រកចេញចូលតែមួយ | x | x | x | x | x | x | x | x | x | x | x | x | នា.រដ្ឋបាល | រដ្ឋ |
| ៣.១.៥ រៀបចំអោយមានដំណើរការឡើងវិញនូវប្រព័ន្ធ Network ក្រសួង | x | x | x | x | x | x | x | x | x | x | x | x | នា.រដ្ឋបាល | រដ្ឋ |
| ៣.១.៦ រៀបចំបំពេញបែបបទ និងនីតិវិធីក្នុងការស្នើសុំតែងតាំងប្រគលភារកិច្ចជូនមន្ត្រីរាជការ | x | x | x | x | x | x | x | x | x | x | x | x | នា.បុគ្គលិក | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.១.៧ រៀបចំបំពេញបែបបទ ស្នើសុំផ្តល់គ្រឿងឥស្សរិយសជូនមន្ត្រីរាជការ | x | x | x | x | x | x | x | x | x | | | | នា.បុគ្គលិក | រដ្ឋ |
| ៣.១.៨ រៀបចំបំពេញបែបបទ ស្នើសុំតម្លើងឋានន្តរសក្តិជូនមន្ត្រីរាជការឲ្យស្របនឹងមុខតំណែង | x | x | x | x | x | x | x | x | x | x | x | x | នា.បុគ្គលិក | រដ្ឋ |
| ៣.១.៩ រៀបចំបំពេញបែបបទ ស្នើសុំតម្លើងថ្នាក់ជូនមន្ត្រីរាជការ | x | x | x | x | | | | | | | | | នា.បុគ្គលិក | រដ្ឋ |
| ៣.១.១០ រៀបចំបំពេញបែបបទ ស្នើសុំរំកិលប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការ | x | x | x | x | x | x | x | x | x | x | x | x | នា.បុគ្គលិក | រដ្ឋ |
| ៣.១.១១ រៀបចំបំពេញបែបបទចូលនិវត្តន៍ជូនមន្ត្រីរាជការដែលដល់អាយុឲ្យចូលនិវត្ត | x | x | x | x | x | x | x | x | x | x | x | x | នា.បុគ្គលិក | រដ្ឋ |
| ៣.១.១២ រៀបចំបែបបទប្រឡងជ្រើសរើសក្របខណ្ឌថ្មី | x | x | x | x | x | x | | | | | | | នា.បុគ្គលិក | រដ្ឋ |
| ៣.១.១៣ រៀបចំបែបបទប្រឡងផ្ទៃក្នុងផ្លាស់ប្តូរប្រភេទក្របខណ្ឌ | | | | | | | x | x | x | x | x | x | នា.បុគ្គលិក | រដ្ឋ |
| **ផែនការអាទិភាពទី២. ពង្រឹង ពង្រីកបទដ្ឋានគតិយុត្ត និងបណ្តាយន្តការពាក់ព័ន្ធនឹងវិស័យវប្បធម៌** | | | | | | | | | | | | | | |
| ៣.២.១ បន្តអប់រំផ្សព្វផ្សាយច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ និងបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធដល់ការការពារ និងថៃរក្សាស្ថានីយបុរាណ និងរមណីយដ្ឋានប្រវត្តិសាស្រ្ត និងតាមបណ្តាខេត្ត | | | | | | | | | | x | x | | នា.បុរាណវិទ្យា | រដ្ឋ |
| ៣.២.២ បន្តពង្រឹងការអនុវត្តច្បាប់ ស្តីពីការការពារបេតិកភណ្ឌវប្បធម៌ និងច្បាប់ពាក់ព័ន្ធផ្សេងៗ (៣កន្លែង) បន្តរៀបចំធ្វើស្លាកសញ្ញាបង្ហាញពីទោសបញ្ញាត្តចំពោះអ្នកជួញដូរបុរាណវត្ថុខុសច្បាប់ (ដាក់តាមទីតាំងអាទិភាពដូចជា: ទីផ្សារលក់វត្ថុសិល្បៈច្រកអន្តរជាតិសំខាន់ៗ និងតាមបណ្តាស្ថានីយប្រវត្តិសាស្រ្តសំខាន់ៗ) (លើទីតាំងសំខាន់ៗចំនួន១០កន្លែង) | x | x | x | x | x | x | x | x | x | x | x | x | នា.បុរាណវត្ថុ | រដ្ឋ |
| ៣.២.៣ រៀបចំប្រកាស ស្តីពីបែបបទ និងលក្ខខណ្ឌថតភាពយន្តរបស់ផលិតករបរទេស | x | | | | | | | | | | | | នា.នីតិកម្ម<br>និងភាពយន្ត | រដ្ឋ |
| ៣.២.៤ ធ្វើវិសោធនកម្មអនុក្រឹត្យលេខ៦៣ អនក្រ.បក ស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យភាពយន្ត វីដេអូ | | | | | | | | | | x | | | នា.នីតិកម្ម និង<br>ភាពយន្ត | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.២.៥ រៀបចំប្រកាស ស្ដីពីការគ្រប់គ្រងសំណង់ប្រវត្តិសាស្រ្ត | | | | | | | | | | | x | | នា.នីតិកម្ម និង អគ្គនាយកបេតិកភណ្ឌ | រដ្ឋ |
| ៣.២.៦ រៀបចំប្រកាស ស្ដីពីការគ្រប់គ្រងសារមន្ទីរ | | | | | | | | | x | | | | នីតិកម្ម និងសារមន្ទីរ | រដ្ឋ |
| ៣.២.៧ រៀបចំប្រកាស ស្ដីពីបែបបទ និងលក្ខខណ្ឌក្នុងការស្នើរសុំបើក បិទ និងប្ដូរទីតាំងសារមន្ទីរ | | | | | | | | | | x | | | នា.នីតិកម្ម និងសារមន្ទីរ | រដ្ឋ |
| ៣.២.៨ រៀបចំប្រកាស ស្ដីពីការចុះបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ជាតិ | x | | | | | | | | | | | x | នា.នីតិកម្ម និងបុរាណវិទ្យា | រដ្ឋ |
| ៣.២.៩ រៀបចំប្រកាសស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការច្រកចេញចូលតែមួយក្នុង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | | x | | | | | | | | | | នា.នីតិកម្ម និងបុគ្គលិក | រដ្ឋ |
| ៣.២.១០ រៀបចំប្រកាស ស្ដីពីការបែងចែកភារកិច្ចលើការងារគ្រប់គ្រង ការប្រមូលចំណូល ពីការផ្ដល់សេវាសាធារណៈ | | | | | x | | | | | | | | នា.នីតិកម្ម និងគណនេយ្យ | រដ្ឋ |
| ៣.២.១១ រៀបចំលិខិតបទដ្ឋានគតិយុត្តិទាក់ទងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល | | | | | | | x | x | x | x | x | x | នា.សិទ្ធិអ្នកនិពន្ធ | រដ្ឋ |
| ៣.២.១២ បន្តតាមដានសេចក្ដីព្រាងអនុក្រឹត្យអង្គភាពគ្រប់គ្រងសិទ្ធិរួមនៅទីស្ដីការគណៈរដ្ឋមន្ត្រី | | | | | | | x | | | | | | នា.សិទ្ធិអ្នកនិពន្ធ | រដ្ឋ |
| ៣.២.១៣ រៀបចំយន្តការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា | x | x | x | x | x | x | x | x | x | x | x | x | នា.រដ្ឋបាល | រដ្ឋ |
| ៣.២.១៤ រៀបចំឯកសារច្បាប់ ស្ដីពីការគ្រប់គ្រងសារមន្ទីរ | | | | | | | | | | x | | | នា.សារមន្ទីរ និងនីតិកម្ម | រដ្ឋ |
| ៣.២.១៥ ធ្វើសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងសិល្បភាពយន្ត | x | x | x | x | x | x | x | x | x | x | x | x | នា.ភាពយន្ត | រដ្ឋ |
| ៣.២.១៦ រៀបចំយន្តការគ្រប់គ្រង និងការបម្រើសេវានៅតាមបណ្ដាសារមន្ទីរដើម្បីបង្កលក្ខណៈសេវាកម្មឲ្យកាន់តែប្រសើរឡើង | x | x | x | x | x | x | x | x | x | x | x | x | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| **ផែនការអាទិភាពទី៣. លើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សលើវិស័យសិល្បៈវប្បធម៌** | | | | | | | | | | | | | | |
| ៣.៣.១ បើកវគ្គបណ្ដុះបណ្ដាលស្ដីពីការងារចុះបញ្ជីសារពើភណ្ឌបុរាណវត្ថុ ដល់មន្ត្រីវប្បធម៌រាជធានី ខេត្ត | | | | | | | | | | | | | នា.បុរាណវត្ថុ | រដ្ឋ |
| ៣.៣.២ បើកវគ្គបណ្ដុះបណ្ដាលជំនាញ ស្ដីពីការអភិរក្សវត្ថុ | | | | | | | | | | | | | នា.បុរាណវត្ថុ | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បុរាណ ដល់មន្ត្រីវប្បធម៌រាជធានី ខេត្ត | | | | | | | | | | | | | | |
| ៣.៣.៣ បើកវគ្គបណ្តុះបណ្តាលការងារផ្តល់សេវា លើវិស័យសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម | | | | | | | | x | | | | | សាលាបណ្តុះបណ្តាលក្រប ខណ្ឌវប្បធម៌ | រដ្ឋ |
| ៣.៣.៤ បើកវគ្គបណ្តុះបណ្តាល ស្តីពីការងារចុះបញ្ជីសារពើភណ្ឌបុរាណវត្ថុ ដល់មន្ត្រីសារមន្ទីរខេត្ត | | | | | | | x | x | | | | | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| ៣.៣.៥ បើកវគ្គបណ្តុះបណ្តាលមគ្គុទេសក៍សារមន្ទីរ ដល់មន្ត្រីសារមន្ទីរខេត្ត | | | | | | | x | x | | | | | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| ៣.៣.៦ បើកវគ្គបណ្តុះបណ្តាលជំនាញអភិរក្សវត្ថុសិល្បៈ ដល់មន្ត្រីខេត្ត-ក្រុង | | | | | | x | | | | | | | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| ៣.៣.៧ បើកវគ្គវិក្រិតការជំនាញមគ្គុទេសក៍សារមន្ទីរ | | | | | | | x | x | | | | | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| ៣.៣.៨ បណ្តុះបណ្តាលជំនាញ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេសនៅសារមន្ទីរជាតិ | | | | | x | x | | | | | | | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| ៣.៣.៩ បណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេសនៅសារមន្ទីរខេត្ត-ក្រុង | | | | | | | x | | | | | | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| ៣.៣.១០ បើកបណ្តុះបណ្តាល និងណែនាំដល់មន្ត្រីជួសជុលរូបនៅសារមន្ទីខេត្ត-ក្រុង | | | | | | | | x | | | | | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| ៣.៣.១២ បើកវគ្គបណ្តុះបណ្តាលជំនាញគ្រប់គ្រងវត្ថុបុរាណដល់មន្ត្រីរាជធានី-ខេត្ត | | | | | | | | x | | | | | នា.សារមន្ទីរ | រដ្ឋ និងដៃគូ |
| ៣.៣.១៣ បើកវគ្គបណ្តុះបណ្តាល ស្តីពីការងារចុះបញ្ជីសារពើភណ្ឌស្ថានីយបុរាណ និងសំណង់បុរាណដល់មន្ត្រីសារមន្ទីរខេត្ត | | | | | | | | | | | | | នា.គាំពារ និងបុរាណវិទ្យា | រដ្ឋ |
| ៣.៣.១៤ បើកវគ្គបំប៉នជំនាញរយៈពេលខ្លី **ថតភាពយន្ត** | | | x | | | | | | | | | | នា.ភាពយន្ត | រដ្ឋ |
| ៣.៣.១៥ បើកវគ្គបំប៉នជំនាញរយៈពេលខ្លី **បច្ចេកទេសពន្លឺ** | | | | x | | | | | | | | | នា.ភាពយន្ត | រដ្ឋ |
| ៣.៣.១៦ បណ្តុះបណ្តាលជំនាញ **អ្នកដឹកនាំរឿង** | | | | | x | x | x | x | x | x | | | នា.ភាពយន្ត | រដ្ឋ |
| ៣.៣.១៧ ចុះបំប៉នមន្ត្រីរាជការ ស្តីពីរបៀបគ្រប់គ្រងសិល្បៈសូនរូប និងសិល្បៈសិប្បកម្មតាមបណ្តាខេត្ត-ក្រុង ចំនួន៤ខេត្ត | x | x | x | x | x | x | x | x | x | x | x | x | នា.សិល្បៈសូនរូប | រដ្ឋ |
| **ផែនការអាទិភាពទី៤. បន្តពង្រឹងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្មសាធារណៈ** | | | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៤.១ រៀបចំកសាងឯកសារកិច្ចការលទ្ធកម្មប្រចាំឆ្នាំ២០១៤ | x | | | | | | | | | | | | នា.សំភារៈ និងបរិក្ខារ | រដ្ឋ |
| ៣.៤.២ អនុវត្តកិច្ចការលទ្ធកម្មប្រចាំឆ្នាំ២០១៤ | x | x | x | x | x | x | x | x | | | | | នា.សំភារៈ និងបរិក្ខារ | រដ្ឋ |
| ៣.៤.៣ រៀបចំការផ្គត់ផ្គង់សម្ភារៈ បរិក្ខារ និង សម្ភារៈការិយាល័យជូនអង្គភាពនានា | x | x | x | x | x | x | x | x | x | x | x | x | នា.សំភារៈ និងបរិក្ខារ | រដ្ឋ |
| ៣.៤.៤ រៀបចំឯកសារ និងបែបបទ ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង | | | x | x | x | x | | | | | | | នា.សំភារៈ និងបរិក្ខារ | រដ្ឋ |
| ៣.៤.៥ ធ្វើបញ្ជីសារពើភណ្ឌ និងផ្ទៀងផ្ទាត់បញ្ជីទ្រព្យសម្បត្តិរដ្ឋ | x | x | x | x | x | x | x | x | x | x | x | x | នា.សំភារៈ និងបរិក្ខារ | រដ្ឋ |
| ៣.៤.៦ រៀបចំឯកសារស្នើសុំថវិកា ដើម្បីជួសជុលហេដ្ឋារចនាសម្ព័ន្ធនានា | | x | x | x | | | | | | | | | នា.សំភារៈ និងបរិក្ខារ | រដ្ឋ |
| ៣.៤.៧ រៀបចំស្នើសុំថវិកា ដើម្បីជួសជុលសម្ភារៈបរិក្ខាចាស់ៗ និងខូច នៅតាមការិយាល័យនានា ដើម្បីបំរើការដល់ដំណើរការការងារក្រសួង | | x | x | x | | | | | | | | | នា.សំភារៈ និងបរិក្ខារ | រដ្ឋ |
| ៣.៤.៨ តាមដានគម្រោងជួសជុល និងការសាងសង់ផ្សេងៗតាមអង្គភាព និងមន្ទីររាជធានី ខេត្ត | | x | x | x | x | x | x | | | | | | នា.សំភារៈ និងបរិក្ខារ | រដ្ឋ |
| ៣.៤.៩ រៀបចំឯកសារចំណាយឆ្នាំ២០១៣ ដែលនៅសល់សម្រាប់ទូទាត់ក្នុងថវិកាឆ្នាំ២០១៤ | x | x | | | | | | | | | | | នា.គណនេយ្យ | រដ្ឋ |
| ៣.៤.១០ រៀបចំឯកសារទូទាត់រដ្ឋទេយ្យបុរេប្រទានសម្រាប់ផជុំ | x | x | x | x | x | x | x | x | x | x | x | x | នា.គណនេយ្យ | រដ្ឋ |
| ៣.៤.១១ ធ្វើថវិការដ្ឋលើឯកសារថ្លៃទឹក អគ្គីសនី សំរាម និងទូរស័ព្ទសំរាប់ទូទាត់ជូនទីស្តីការក្រសួង និងបណ្តាអង្គភាពក្រោមឱវាទក្រសួង | x | x | x | x | x | x | x | x | x | x | x | x | នា.គណនេយ្យ | រដ្ឋ |
| ៣.៤.១២ ធ្វើកម្មវិធីចំណូល ចំណាយប្រចាំខែ និងប្រចាំត្រីមាស | x | x | x | x | x | x | x | x | x | x | x | x | នា.គណនេយ្យ | រដ្ឋ |
| ៣.៤.១៣ ប្រមូលរបាយការណ៍ចំណាយប្រចាំឆ្នាំ របស់រដ្ឋបាលកណ្តាល និងរបាយការណ៍ថវិការបស់មន្ទីរជំនាញថ្នាក់រាជធានីខេត្ត ផ្ទៀងផ្ទាត់តួលេខជាមួយអគ្គនាយកដ្ឋានរតនាគាជាតិ | | | | | | | | | | | | x | នា.គណនេយ្យ | រដ្ឋ |
| ៣.៤.១៤ ចុះបញ្ជីបេឡា របាយកាណ៍បេឡាប្រចាំថ្ងៃនិងប្រចាំខែ | x | x | x | x | x | x | x | x | x | x | x | x | នា.គណនេយ្យ | រដ្ឋ |
| ៣.៤.១៥ រៀបចំឯកសារជូនទៅការិយាល័យជំរះបញ្ជីធ្វើការ | x | x | x | x | x | x | x | x | x | x | x | x | នា.គណនេយ្យ | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ត្រួតពិនិត្យ | | | | | | | | | | | | | | |
| ៣.៤.១៦ ធ្វើរបាយការណ៍ និងសាលាកប័ត្របង់ចំណូលចូលថវិការដ្ឋដូចខាងក្រោម៖<br>-ចំណូលលក់សំបុត្រជូនភ្ញៀវជាតិ និងអន្តរជាតិចូលទស្សនាសារមន្ទីរ<br>-ចំណូលត្រួតពិនិត្យកាស្សែតវីដេអូ<br>-ចំណូលត្រួតពិនិត្យវត្ថុសិល្បៈនាំចេញ-ចូល<br>-ចំណូលសុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃអ្នកទទួលមរតក<br>-ចំណូលជួលទីតាំងមួយផ្នែករបស់នាយកដ្ឋានអភិវឌ្ឍវប្បធម៌<br>-ចំណាយជួលរោងភាពយន្តលុច្ស<br>-ចំណូលជួលរោងភាពយន្តខេមរិន្ទ | x | x | x | x | x | x | x | x | x | x | x | x | នា.គណនេយ្យ | រដ្ឋ |
| ៣.៤.១៧ ធ្វើតារាងផ្គូរផ្គងចំណូលថវិការដ្ឋ និងលើកគម្រោងផែនការសកម្មភាព និងគម្រោងប្រមូលបំណុលគ្រប់ប្រភេទរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សំរាប់ឆ្នាំ២០១៥ | | | | | | | | | | | | x | នា.គណនេយ្យ | រដ្ឋ |
| ៣.៤.១៨ ធ្វើប្រកាសស្តីពីការតែងតាំង ផ្ទេរសិទ្ធិជូនសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនិងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានីខេត្ត សំរាប់ឆ្នាំ២០១៤ | x | x | x | x | x | x | x | x | x | x | x | x | នា.គណនេយ្យ | រដ្ឋ |
| ៣.៤.១៩ ប្រមូលអាណត្តិ និងឯកសារផ្សេងៗដែលពាក់ព័ន្ធការចំណាយជំពូក៦៤ ដើម្បីផ្ទៀងផ្ទាត់ជាមួយរតនាគារជាតិ<br>-រៀបចំអាណត្តិ និងឯកសារចំណាយជំពូក៦៤<br>-រៀបចំឯកសារត្រួតពិនិត្យជាប្រចាំ<br>-រៀបចំឯកសារសំរាប់ធ្វើរបាយការណ៍ទូទាត់រដ្ឋទេយ្យបុរេប្រទាន<br>-រៀបចំឯកសារធ្វើរបាយការណ៍ទូទាត់បេសកកម្មក្នុងប្រទេស | x | x | x | x | x | x | x | x | x | x | x | x | នា.គណនេយ្យ | រដ្ឋ |
| ៣.៤.២០ បន្តធ្វើការកែទម្រង់ និងធ្វើឲ្យប្រសើរឡើងនូវការងារគ្រប់គ្រងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ | x | x | x | x | x | x | x | x | x | x | x | x | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | |

| ផែនការអាទិភាពទី៥. បន្តជម្រុញការត្រួតពិនិត្យ វាយតម្លៃការអនុវត្តផែនការសកម្មភាព និងការកសាងផែនការ ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ និងយេនឌ័រ | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៥.១ ពិនិត្យមើលការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ នៃកម្មសិទ្ធិបញ្ញា | | x | | | x | x | x | x | x | x | x | x | នា.សិទ្ធិអ្នកនិពន្ធ | រដ្ឋ |
| ៣.៥.២ ធ្វើអធិការកិច្ចអង្គភាព និងមន្ទីរក្រោមឱវាទក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | x | x | x | x | x | x | x | x | x | x | x | x | នា.អធិការដ្ឋាន | រដ្ឋ |
| ៣.៥.៣ ធ្វើអធិការកិច្ចបណ្ដាផលិតកម្ម អាជីវកម្ម និងសេវាកម្ម | | x | | | x | | | x | | | x | | នា.អធិការដ្ឋាន | រដ្ឋ |
| ៣.៥.៤ អង្កេត ស្រាវជ្រាវបណ្ដឹង វិវាទរដ្ឋបាល និងបទល្មើសក្នុងសមត្ថកិច្ចក្រសួង | | | x | | | x | | | x | | | x | នា.អធិការដ្ឋាន | រដ្ឋ |
| ៣.៥.៥ ចុះធ្វើសវនកម្មតាមបណ្ដាមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានី ខេត្ត | x | x | x | x | x | x | x | x | x | | | | នា.សវនកម្ម | រដ្ឋ |
| ៣.៥.៦ ចុះធ្វើសវនកម្មតាមបណ្ដាអង្គភាពថ្នាក់កណ្ដាល | | | | | | | | | | x | x | x | នា.សវនកម្ម | រដ្ឋ |
| ៣.៥.៧ រៀបចំរបាយការណ៍ ស្ដីពីលទ្ធផលការងារការធ្វើសវនកម្មជូនលោកជំទាវរដ្ឋមន្ត្រី នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ | x | x | x | x | x | x | x | x | x | x | x | x | នា.សវនកម្ម | រដ្ឋ |
| ៣.៥.៨ រៀបចំបោះពុម្ពសៀវភៅផែនការយុទ្ធសាស្ត្រឆ្នាំ២០១៣-២០១៥ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង | x | | | | | | | | | | | | នា.សវនកម្ម | រដ្ឋ |
| ៣.៥.៩ បន្តចុះពង្រឹងការងារគ្រប់គ្រងមន្ត្រីរាជការ រៀបចំបញ្ចូលព័ត៌មានមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា និងបន្តផ្សព្វផ្សាយច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល | x | x | x | x | x | x | x | x | x | x | x | x | នា.បុគ្គលិក | រដ្ឋ |
| ៣.៥.១០ រៀបចំផែនការសកម្មភាពការងារវប្បធម៌ឆ្នាំ២០១៥ | | | | x | x | | | | | | | | នា.ផែនការ ស្ថិតិ | រដ្ឋ |
| ៣.៥.១១ ប្រមូលទិន្នន័យគម្រោងវិនិយោគសាធារណៈដែលបានអនុវត្តនៅឆ្នាំ២០១៤ | | | | | | | | | | | | | នា.ផែនការ ស្ថិតិ | រដ្ឋ |
| ៣.៥.១២ រៀបចំផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល២០១៥-២០១៧ | | | | | | | | | | | | | នា.ផែនការ ស្ថិតិ | រដ្ឋ |
| ៣.៥.១៣ ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារវប្បធម៌ និង | x | x | x | x | x | x | x | x | x | x | x | x | នា.ផែនការ ស្ថិតិ | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វិចិត្រសិល្បៈ ប្រចាំខែ ឆមាស និងឆ្នាំ | | | | | | | | | | | | | | |
| ៣.៥.១៤ ប្រមូល ចងក្រង និងធ្វើការបោះពុម្ពសៀវភៅស្ថិតិវប្បធម៌ឆ្នាំ២០១៤ | | | | | | | | | | | x | x | នា.ផែនការ ស្ថិតិ | រដ្ឋ |
| ៣.៥.១៥ បោះពុម្ពសៀវភៅសមិទ្ធផលវប្បធម៌ ឆ្នាំ២០១៤ | | | | | | | | | | | | x | នា.ផែនការ ស្ថិតិ | រដ្ឋ |
| ៣.៥.១៦ ចុះណែនាំពីការកសាងផែនការ និងរបៀបធ្វើរបាយការណ៍ឲ្យបានត្រឹមត្រូវដល់មន្ត្រីទទួលបន្ទុកថ្នាក់រាជធានី-ខេត្ត | x | x | x | x | x | x | x | x | x | x | x | x | នា.ផែនការ ស្ថិតិ | រដ្ឋ |
| ៣.៥.១៧ ចុះតាមដានអនុវត្តផែនការរបស់មន្ទីរវប្បធម៌ រាជធានី ខេត្ត | x | x | x | x | x | x | x | x | x | x | x | x | នា.ផែនការ ស្ថិតិ | រដ្ឋ |
| ៣.៥.១៨ លើកគម្រោងផែនការថវិកាសុំប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភសង្គមកិច្ចជូនមន្ត្រីរាជការសំរាប់ឆ្នាំ២០១៥ | | | | x | x | x | x | | | | | | នា.គណនេយ្យ | រដ្ឋ |
| ៣.៥.១៩ បើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការដល់មន្ត្រីក្របខណ្ឌថ្មីឆ្នាំ២០១៣ | | | | | | | x | | | | | | សាលាបណ្តុះបណ្តាលក្រប ខណ្ឌវប្បធម៌ | រដ្ឋ |
| ៣.៥.២០ បើកវគ្គរដ្ឋបាល និងគ្រប់គ្រង ដល់មន្ត្រីរាជការក្របខណ្ឌក្រសួង | | | | | | | | | x | | | | សាលាបណ្តុះបណ្តាលក្រប ខណ្ឌវប្បធម៌ | រដ្ឋ |
| ៣.៥.២០ បណ្តុះបណ្តាលមន្ត្រីរាជការលើ ជំនាញបច្ចេកវិទ្យាព័ត៌មាន | | | | | | | x | x | x | | | | នា.រដ្ឋបាល | រដ្ឋ |
| ៣.៥.២១ បើកវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ច | | | | | | | | | | x | | | នា.អធិការដ្ឋាន | រដ្ឋ |
| ៣.៥.២២ ត្រួតពិនិត្យការអនុវត្តការងារជាមួយអង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួង | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៥.២៣ ពង្រឹងសមត្ថភាព គ្រូបង្ហាត់ និងបង្រៀន | | | | | | | | | | | | | សាលាមធ្យមវិចិត្រសិល្បៈ | រដ្ឋ |
| ៣.៥.២៤ ជំរុញការបណ្តុះបណ្តាលគ្រូបឋមសិក្សា មធ្យមសិក្សាកំរិត១ និងគ្រូកំរិតឧត្តម | | | | | | | | | | | | | សាលាមធ្យមវិចិត្រសិល្បៈ | រដ្ឋ |
| ៣.៥.២៥ លើកកម្ពស់តួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត | | | | | | | | | | | | | សាលាមធ្យមវិចិត្រសិល្បៈ | រដ្ឋ |
| **ផែនការអាទិភាពទី៦. បន្តពង្រឹងភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល ដៃគូឯកជន អង្គការជាតិ និងអន្តរជាតិ** | | | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៦.១ បន្តធ្វើការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ | | | | | | | x | | | | | | នា.សិទ្ធិអ្នកនិពន្ធ | រដ្ឋ |
| ៣.៦.២ បន្តធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.៣ ត្រៀមទទួលគណៈប្រតិភូថ្នាក់រដ្ឋមន្ត្រីមកពីសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតចិន | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.៤ ត្រៀមបញ្ជូនមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកវប្បធម៌ និងសិល្បៈអាស៊ាន ទៅប្រទេសវៀតណាម | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.៥ រៀបចំទទួលគណៈប្រតិភូថ្នាក់មន្ត្រីជំនាញមកពីសាធារណរដ្ឋប្រជាមានិតចិន សហព័ន្ធរុស្ស៊ី និងម៉ាឡេស៊ី | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.៦ រៀបចំទទួលគណៈប្រតិភូសិល្បៈមកពីសាធារណរដ្ឋសង្គមនិយមវៀតណាម និងឡាវ | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.៧ រៀបចំកិច្ចប្រជុំលើកទី៤៩នៃគណៈកម្មាធិការអាស៊ានផ្នែកវប្បធម៌ ព័ត៌មាន | | | | | | | | | | | x | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.៨ ត្រៀមបញ្ជូនក្រុមសិល្បៈទៅចូលរួមមហោស្រពសិល្បៈអាស៊ាន ដើម្បីអបអរត្រៀមចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងសិល្បៈអាស៊ាន | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.៩ ត្រៀមចូលរួមកិច្ចប្រជុំអនុគណៈកម្មាធិការផ្នែកវប្បធម៌នៅហ្វីលីពីន | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.១០ ត្រៀមទទួលរៀបចំកិច្ចប្រជុំគណៈកម្មាធិការអាស៊ានផ្នែកវប្បធម៌ និងព័ត៌មាននៅខេត្តសៀមរាប | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.១១ត្រៀមទទួលរៀបចំមហោស្រពសិល្បៈជនជាតិអាស៊ាន | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.១២ បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូ ដែលជាអង្គការជាតិ អន្តរជាតិ និងសមាគមផ្សេងៗដែលប្រតិបត្តិលើវិស័យវប្បធម៌ទាំងរូបី និងអរូបី | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៦.១៣ ធ្វើទំនាក់ទំនងបន្ថែមជាមួយអង្គការអន្តរជាតិលើវិស័យសិល្បៈវប្បធម៌ | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.១៤ ត្រៀមរៀបចំចុះហត្ថលេខាផ្លាស់ប្តូរវប្បធម៌កម្ពុជា ជាមួយបង់ក្លាដេស ហ្វីលីពីន និងវៀតណាម | | | | | | | | | | | | | នា.សហប្រតិបត្តិការអន្តរជាតិ | រដ្ឋ |
| ៣.៦.១៥ បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គការ ស្ថាប័នអន្តរជាតិនានា សាកលវិទ្យាល័យក្នុង និងក្រៅប្រទេសដែលជាដៃគូអភិវឌ្ឍក្នុងការបង្កើតកម្មវិធីថ្នាក់អនុបណ្ឌិត និងបណ្ឌិត | | | | x | x | | | | | | | | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | រដ្ឋ |
| ៣.៦.១៦ បន្តពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ ដើម្បីស្វែងរកជំនួយអភិវឌ្ឍមហាវិទ្យាល័យរួមមាន ជប៉ុន កូរ៉េ និងអាល្លឺម៉ង់ | | | | | | | | | | | | | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | |
| ៣.៦.១៧ បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាង INALCO (វិទ្យាស្ថានជាតិនៃភាសា និងអារ្យធម៌ចុងបូព៌ា) និងសាកលវិទ្យាល័យមូសុងនៃប្រទេសបារាំងឲ្យកាន់តែទូលំទូលាយ | | | | | | | | | | | | | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | |
| ៣.៦.១៨ ចុះកិច្ចព្រមព្រៀងជាមួយភាគីភាពយន្តចិន | | | | | | | | | | | x | | នា.ភាពយន្ត | រដ្ឋ |
| ៣.៦.១៩ ចូលរួមកិច្ចប្រជុំសមាគមភាពយន្តអាស៊ីនៅ ពូសាន | | | | | | | | | | x | | | នា.ភាពយន្ត | រដ្ឋ |
| ៣.៦.២០ ជម្រុញការអនុវត្តកិច្ចព្រមព្រៀង **សហផលិតកម្ម** | x | x | x | x | x | x | x | x | x | x | x | x | នា.ភាពយន្ត | រដ្ឋ |
| ៣.៦.២១ ចូលរួមកិច្ចប្រជុំ និងពិព័រណ៍ភាពយន្តអាស៊ាន | | | | | | x | | | | | | | នា.ឥភាពយន្ត | រដ្ឋ |

## ៧.លទ្ធផលរំពឹងទុក

**អនុវត្តសម្រេចបានតាមផែនការខាងលើ យើងសង្ឃឹមថានឹងទទួលបាននូវលទ្ធផលជាវិជ្ជមាន ស្របតាមការរំពឹងទុកដូចខាងក្រោម:**

១.ស្នាដៃសិល្បៈទស្សនីយភាព សិល្បៈសូនរូប និងសិប្បកម្ម កាន់តែពង្រឹងបាននូវគុណភាព និងបរិមាណដែលជាកត្តាអាចទាក់ទាញភ្ញៀវជាតិ អន្តរជាតិ ចូលមកទស្សនាកម្ពុជា ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន

២.ទាក់ទាញបាននូវម្ចាស់ផលិតកម្មភាពយន្តបរទេសឲ្យចូលមកថតខ្សែភាពយន្ត វីដេអូ នៅកម្ពុជាកាន់តែច្រើនថែមទៀត

៣.ផលិតផលវប្បធម៌នឹងត្រូវបានផ្សព្វផ្សាយទូទាំងពិភពលោក

៤.ទប់ស្កាត់ និងកាត់បន្ថយបាននូវលំហូរវប្បធម៌អវិជ្ជមានពីបរទេស

៥.ថែរក្សា និងលើកតម្កើងកេរដំណែលវប្បធម៌ ប្រពៃណី ទំនៀមទំលាប់ជាតិ ជនជាតិដើម ភាគតិច និងបង្កើនសកម្មភាពអភិវឌ្ឍវប្បធម៌គ្រប់ជំនាញនៅមូលដ្ឋាន

៦.សកត្តានុពលវប្បធម៌នឹងក្លាយជាកម្លាំងចលករប្រកបដោយប្រសិទ្ធភាពក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ

៧.ថែរក្សា ការពារបានកាន់តែប្រសើរឡើងទៀតនូវអត្តសញ្ញាណវប្បធម៌ជាតិក្នុង ដំណាក់កាលលំហូរសេរីនៅតំបន់អាស៊ាននឆ្នាំ២០១៥។

**បានពិនិត្យ និងបញ្ជូនមកលោកជំទាវរដ្ឋមន្ត្រី**

**បានឃើញ និងឯកភាព** **ដើម្បីសម្រេច**

| | | |
|---|---|---|
| រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០១៤ | រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០១៤ | រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០១៤ |
| **រដ្ឋមន្ត្រី** | **អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ** | **ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសរុប** |